## ឃ្លាំមើលសភា និង តំណាងរាស្ត្រសំរាប់មករា ឆ្នាំ២០០៨

បន្ទាប់ពីការប្រជុំអស់រយៈពេល ៣ ខែ (តុលា-ធ្នូ) រដ្ឋសភាក្នុងខែ មករា នេះ មិនបានសម្រាកវិស្សមកាលរបស់ខ្លួនដូចលើកមុនៗទេ ដោយសម័យប្រជុំលើកទី ៧ នេះ នឹងត្រូវបន្តរហូតដល់ខែ មីនា។ បើតាមប្រសាសន៍របស់សម្តេចមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភាជាតិបានឱ្យដឹងថា រដ្ឋសភានឹងសម្រាកវិស្សមកាលរបស់ខ្លួនចាប់ពីខែ មេសា ទៅ ដោយសារតែប្រទេសកម្ពុជានឹងមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅខែ កក្កដា។ ទោះបីយ៉ាងណា ក្នុងខែ មករា នេះ រដ្ឋសភាបានអនុម័តសេចក្តីព្រាងច្បាប់ចំនួន ៣ ដោយបានបើកសម័យប្រជុំពេញអង្គរបស់ខ្លួន តែ ២ ព្រឹកប៉ុណ្ណោះ បើទោះបីជាមានសេចក្តីព្រាងច្បាប់មួយចំនួនទៀតត្រូវបានគណៈកម្មការជំនាញរដ្ឋសភាបានពិភាក្សាចប់សព្វគ្រប់ក៏ដោយ។ ជាមួយគ្នានេះដែរ ចាប់តាំងពីរដ្ឋសភាបានផ្លាស់ប្តូរទៅទីតាំងថ្មីមក សង្គមស៊ីវិល ក៏ដូចជាម្ចាស់ឆ្នោត ជួបប្រទះនូវការលំបាកក្នុងការផ្ញើឯកសារ ឬអនុសាសន៍នានាទាក់ទងនឹងសេចក្តីព្រាងច្បាប់ទៅឱ្យអ្នកតំណាងរាស្ត្រទាំង ១២៣ រូប ដោយរដ្ឋបាលរដ្ឋសភាតម្រូវឱ្យដាក់ក្នុងស្រោមសំបុត្រ និងគោរពជូនអ្នកតំណាងរាស្ត្រនិមួយៗ។ ប្រការនេះ ប្រសិនបើសង្គមស៊ីវិល ឬម្ចាស់ឆ្នោតចង់ផ្ញើឯកសារទៅតំណាងរាស្ត្រទាំង ១២៣ រូប គឺត្រូវដាក់ក្នុងស្រោមសំបុត្រចំនួន ១២៣ សន្លឹក។

ក្នុងរយៈពេលពិភាក្សា ២ ព្រឹកនេះ ខុមហ្វ្រែល សង្កេតឃើញថា អ្នកតំណាងរាស្ត្រនៅតែបន្តវាយប្រហារ គ្នាទៅវិញទៅមក និងលើកឡើងពីគណបក្សរបស់ខ្លួន ដោយបានផ្តោតការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះទៅលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់។

សេចក្តីព្រាងច្បាប់ដែលសភាអនុម័តនៅក្នុងខែនេះរួមមាន:

- សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៤៥ថ្មី និង ១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និង ជប៉ុន ស្តីពីសេរីភាវូបនីយកម្ម ការជំរុញ និងការការពារវិនិយោគ។
- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ១ របស់អាស៊ានស្តីពីការកំណត់ផ្លូវ និងមធ្យោបាយបំពាក់លើផ្លូវដឹកជញ្ជូនឆ្លងកាត់សម្រាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលទំនិញឆ្លងកាត់។

## ការចុះទៅកាន់មណ្ឌលនានារបស់អ្នកតំណាងរាស្ត្រ

ក្រាហ្វិចទី១: ភាគរយអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន នៃគណបក្សនីមួយៗធៀបនឹងគណបក្សរបស់ខ្លួន




នៅក្នុងខែមករានេះ ដោយសារសភាធ្វើការប្រជុំតែ ២ព្រឹក តាមព័ត៌មានដែលខុមហ្វ្រែលបានទទួលបង្ហាញថា មានអ្នកតំណាងរាស្ត្រច្រើនបានចុះមូលដ្ឋានធៀបនឹងខែមុនដែលសភាបើកសម័យប្រជុំពេញអង្គរបស់ខ្លួនរហូតដល់ ១៣ព្រឹក ហើយមានអ្នក-តំណាងរាស្ត្រប្រមាណ ៣២ រូប បានចុះមូលដ្ឋានប្រមាណ ១០០ លើក។ ដោយឡែកក្នុងខែ មករា នេះ មានអ្នកតំណាងរាស្ត្រយ៉ាងតិចចំនួន ៤៥ រូប បានចុះមូលដ្ឋានចំនួន ១៥៥ លើក។ មណ្ឌល បាត់ដំបង នៅតែជាមណ្ឌលដែលមានតំណាងរាស្ត្រចុះទៅច្រើនជាងគេ ដដែល ដែលមានចំនួនរហូតដល់ ៤៦ លើក។ ចំណែកមណ្ឌលដែល ខុមហ្វ្រែល មិនបាន ទទួលព័ត៌មានថា មានអ្នកតំណាងរាស្ត្រចុះរួមមានមណ្ឌល ប៉ៃលិន និង កំពង់ចាម។ ដូចខែមុនៗដែរ គោលបំណងរបស់អ្នកតំណាងរាស្ត្រចុះទៅកាន់មូលដ្ឋានមានដូចជា ចូលរួមក្នុងវេទិកា ចុះអមដំណើរថ្នាក់ដឹកនាំ ចុះពង្រឹងបណ្តាញគណបក្ស ចុះជួយអន្តរាគមន៍ និងពិសេស ចុះសួរសុខទុក្ខ និងចែកអំណោយ។ ក្នុងចំណោមតំណាងរាស្ត្រទាំង ៤៥ រូប ដែលចុះមូលដ្ឋាន មានអ្នកតំណាងរាស្ត្រមកពីគណបក្ស ប្រជាជនកម្ពុជា ចំនួន ២៩ រូប (ស្មើនឹង ៤០% នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ដែលមានចំនួន ៧៣ រូប) បានចុះទៅកាន់មូលដ្ឋានយ៉ាងតិចចំនួន ៩៦ លើក ឬជាមធ្យមអ្នកតំណាងរាស្ត្រ ១ រូប (ក្នុងចំណោមតំណាងរាស្ត្រគណបក្សនេះដែលបានចុះមូលដ្ឋាន) បានចុះមូលដ្ឋានបានចំនួន ៣ លើក។

ចំណែកតំណាងរាស្ត្រ គណបក្ស សមរង្ស៊ី យ៉ាងតិចចំនួន ១០ រូប (សេនឹង ៤២% នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ដែលមានចំនួន ២៤ រូប) បានចុះមូលដ្ឋានយ៉ាងតិចចំនួន ៤២ លើក (ឬជាមធ្យមអ្នកតំណាងរាស្ត្រគណបក្សនេះ ១ រូប ចុះមូលដ្ឋានបានចំនួន ៤ លើក) ហើយអ្នកតំណាងរាស្ត្រគណបក្ស ហ៊្វុនស៊ិនប៉ិច យ៉ាងតិចចំនួន ៦ រូប (សេនឹង ២៣% នៃ អ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ដែលមានចំនួន ២៦ រូប) បានចុះមូលដ្ឋានយ៉ាងតិចចំនួន ១៧លើក (ឬជាមធ្យមអ្នកតំណាងរាស្ត្រគណបក្សនេះ ១ រូប ចុះមូលដ្ឋានបាន ៣ លើក)។

តារាងទី១: ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងផ្សេងៗដែលខុមហ្វ្រែលទទួលបាន

| **គោលបំណងនៃការចុះមូលដ្ឋាន ចំនួន ១៥៥ លើក នៃអ្នកតំណាងរាស្ត្រចំនួន ៤៥ រូប** | **គណបក្សនយោបាយ** | | | **សរុបនៃគោលបំណង** |
|---|---|---|---|---|
| | ២៩ រូប | ១០ រូប | ៦ រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយនិង ការសម្ពោធសមិទ្ធផលនានា | ៨៤ | ២៨ | ១២ | ៨៤ (៥៤%) |
| ការចុះពង្រឹងផ្ទៃក្នុង និង បណ្តុញគណបក្ស | ២៧ | ៦ | ១ | ៣៤ (២២%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ២១ | ០ | ០ | ២១ (១៣%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៣ | ៥ | ៤ | ១២ (៨%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ១ | ៣ | ០ | ៤ (៣%) |
| **សរុបតាមគណបក្ស** | ៩៦ | ៤២ | ១៧ | ១៥៥ (១០០%) |

តារាងទី១ បានបង្ហាញថា:

- ការសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា នៅតែត្រូវបានអ្នកតំណាងរាស្ត្រមកពីគណបក្សទាំងបីយកចិត្តទុកដាក់ជាងគេដដែល ដែលមានរហូតដល់ ៨៤ លើក (ស្មើនឹង ៥៤% នៃគោលបំណងចុះមូលដ្ឋានសរុប)។ អ្នកតំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា បានធ្វើសកម្មភាពនេះច្រើនជាងគេរហូតដល់ទៅ ៤៤ លើក ខណៈដែលតំណាងរាស្ត្រគណបក្ស សមរង្ស៊ី មាន ២៨ លើក និងគណបក្ស ហ៊្វុនស៊ិនប៉ិច មាន ១២ លើក។ ជាឧទាហរណ៍ នៅថ្ងៃទី ១២ ខែ មករា អ្នកតំណាងរាស្ត្រមណ្ឌលបាត់ដំបង ជួញ សុផែ មកពីគណបក្ស ប្រជាជនកម្ពុជា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋក្នុងឃុំ រូងជ្រៃ ចំនួន ២៥៧នាក់។ ក្នុងឱកាសនោះលោកជំទាវបានបានរំលឹកដល់អាជ្ញាធរមូលដ្ឋានឱ្យអប់រំយុវជនឱ្យប្រាសចាកពីអំពើអបាយមុខ។
- អ្នកតំណាងរាស្ត្រមកពីគណបក្សទាំងបី ក៏បានចូលរួមធ្វើសកម្មភាព ចុះពង្រឹងផ្ទៃក្នុង និងបណ្តុញគណបក្ស របស់ខ្លួនផងដែរ ដែលសរុបមាន ៣៤ លើក (សេនឹង ២២% នៃគោលបំណងចុះមូលដ្ឋានសរុប)។ សកម្មភាពនេះត្រូវបាននាំមុខដោយ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលមានចំនួន ២៧ លើក ដូចជាការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ប៉ាល់ សំអឿន មណ្ឌលបន្ទាយមានជ័យដើម្បីបញ្ចុះបឋមសិលាសាងសង់អាគារស្នាក់ការថ្មីគណបក្សប្រជាជនកម្ពុជាស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ក្នុងឱកាសនោះដែរ អ្នកតំណាងរាស្ត្រ ប៉ាល់ សំអឿន បានប្រាប់សមាជិក សមាជិកាបក្សដែលបានចូលរួម ឱ្យរួមគ្នាពង្រឹងគណបក្សថែមទៀត ។
- ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ មានចំនួន ២១ លើក (សេនឹង ១៣% នៃចំនួនការចុះទៅកាន់មូលដ្ឋានសរុប)។ តាមព័ត៌មានដែលខុមហ្វ្រែលទទួលបាន មានតែអ្នកតំណាងរាស្ត្រគណបក្ស ប្រជាជនកម្ពុជា ទេ ដែលចុះអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន ដូចជាការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ញឹម វណ្ណដា និងអ្នកតំណាងរាស្ត្រ ប៉ែន បញ្ញា មណ្ឌលព្រៃវែង ដើម្បីអមដំណើរឯកឧត្តម ស ខេង ក្នុងពិធីបញ្ចុះសីមាវត្ត ប៉ាប្រិយ នៅឃុំ ព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។ ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការ

ចុះអមដំណើរថ្នាក់ដឹកនាំដោយតំណាងរាស្ត្រមកពីគណបក្ស សមរង្ស៊ី និងគណបក្ស ហ្វ៊ុនស៊ិនប៉ិច នោះទេ។

- ការចូលរួមក្នុងវេទិកាសាធារណៈ ត្រូវបានចូលរួមដោយអ្នកតំណាងរាស្ត្រមកពីបីគណបក្សដែលសរុបមានចំនួន ១២ លើក (សេ្មីនឹង ៨% នៃចំនួនចុះទៅកាន់មូលដ្ឋានសរុប)។ តំណាងរាស្ត្រគណបក្ស សមរង្ស៊ី បានចូលរួម ចំនួន ៥ លើក តំណាងរាស្ត្រគណបក្ស ហ្វ៊ុនស៊ិនប៉ិច ៤ លើក និងគណបក្ស ប្រជាជនកម្ពុជា ៣ លើក។ ឧទាហរណ៍ កាលពីថ្ងៃទី ០៥ មករា ឆ្នាំ ២០០៨ អ្នកតំណាងរាស្ត្រមណ្ឌលតាកែវរួមមាន ឯកឧត្តម ចៅ សូផុន មកពីគណបក្សប្រជាជនកម្ពុជា ឯកឧត្តម ហុង សុខហៀង មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និង ឯកឧត្តម គួយ ប៊ុនរឿន មកពីគណបក្ស សមរង្ស៊ី បានអញ្ជើញចូលរួមវេទិកា "អ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត" នៅឃុំ សន្លុង ស្រុកទ្រាំង ខេត្តតាកែវ។
- ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ ដោយអ្នកតំណាងរាស្ត្រមានចំនួនតែ ៤លើក ប៉ុណ្ណោះ (ស្មើនឹង ៣ % នៃការចុះមូលដ្ឋានសរុប)។ ការអន្តរាគមន៍ទាំងនោះភាគច្រើនគឺទាក់ទងនឹងបញ្ហាជម្លោះដីធ្លី ដូចជាការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ មណ្ឌលភ្នំពេញ ទៅកាន់មណ្ឌលកំពង់ធំដើម្បីជួបប្រជាពលរដ្ឋរងគ្រោះ និងជួបអាជ្ញាធរខេត្ត និងមន្ត្រី តុលាការ ឱ្យជួយអន្តរាគមន៍ដោះលែងប្រជាពលរដ្ឋដែលជាប់ឃុំ ដោយសារទំនាស់រឿងដីធ្លីនៅភូមិឡពាង ឃុំពាដេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ក្នុងការជួបនោះ តាមព័ត៌មានដែលខុមហ្វ្រែលទទួលបាន អភិបាលខេត្ត កំពង់ឆ្នាំង បានសន្យាថា នឹងជួយសម្របសម្រួលជាមួយមន្ត្រីតុលាការ និងសន្យាមិនឱ្យក្រុមហ៊ុនធ្វើការឈូសឆាយដីប្រជាពលរដ្ឋ។ ក៏ប៉ុន្តែរហូតមកដល់ពេលនេះតាមព័ត៌មានដែលខុមហ្វ្រែលទទួលបាន មិនទាន់ឃើញមានការដោះលែងនៅឡើយទេ។

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗនាក់ព័ន្ធនឹងសភា និង តំណាងរាស្ត្រ

### អ្នកតំណាងរាស្ត្រយកពេលពិភាក្សាច្បាប់ វាយប្រហារគ្នាទៅវិញទៅមកដោយពាក្យសម្តី

តំណាងរាស្ត្រគណបក្សកាន់អំណាចប្រជាជនកម្ពុជា និងតំណាងរាស្ត្រគណបក្សជំទាស់ សមរង្ស៊ី បានធ្វើការវាយប្រហារពាក្យសម្តីដាក់គ្នារហូតដល់មានការលើកឡើងពីសំណាក់តំណាងរាជរដ្ឋាភិបាលថា ប្រសិនបើអ្នកតំណាងរាស្ត្រ សម រង្ស៊ី គ្មានអភ័យឯកសិទ្ធសភាទេ នោះអ្នកតំណាងរាស្ត្រ សម រង្ស៊ី ប្រាកដជាទទួលរងនូវការប្តឹងផ្តល់ជាមិនខាន ដោយសារតែពាក្យសម្តីរបស់អ្នកតំណាងរាស្ត្ររូបនេះ។

នៅក្នុងសម័យប្រជុំសភាពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពី កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និង ជប៉ុនស្តីពីសេរីភាវូបនីកម្មការជំរុញ និងការការពារវិនិយោគ អ្នកតំណាងរាស្ត្រ សម រង្ស៊ី បានធ្វើការរិះគន់ខ្លាំងៗ ទៅលើរាជរដ្ឋាភិបាល ថាបានប្រព្រឹត្តអំពើពុករលួយយ៉ាងខ្លាំង ហើយថាប្រទេសកម្ពុជាគឺជាប្រទេសពុករលួយជាងគេក្នុងពិភពលោក។ ជាមួយគ្នានេះ អ្នកតំណាងរាស្ត្រ សម រង្ស៊ី ក៏បានធ្វើការរិះគន់ដែរថា ក្រុមហ៊ុនធំៗអន្តរជាតិមិនមកវិនិយោគទេនៅប្រទេសកម្ពុជាទេ តែមានភាគច្រើនគឺជាពួកម៉ាហ្វីយ៉ាដែលចូលចិត្តសូកប៉ាន់ និងប្រព្រឹត្តអំពើពុករលួយ និង អំពើទុច្ចរិត។

អ្នកតំណាងរាស្ត្រ អាយ ខន មកពីគណបក្សកាន់អំណាចប្រជាជនកម្ពុជា បានធ្វើការវាយបកទៅលើអ្នកតំណាងរាស្ត្រ សម រង្ស៊ី ថានិយាយកុហកប្រជាពលរដ្ឋ។ ប្រធានអង្គប្រជុំ ឯកឧត្តម ងួន ញ៉ិល បានហាមការវាយប្រហារពាក្យសម្តីដាក់គ្នាតទៅទៀត ព្រោះវានឹងនាំឱ្យមានការឆ្លើយឆ្លងគ្នាកាន់តែច្រើន។

ទោះបីយ៉ាងណា តំណាងរាជរដ្ឋាភិបាលដែលឡើងមកការពារច្បាប់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម គាត ឈន់ បានបន្តវាយប្រហារអ្នកតំណាងរាស្ត្រ សម រង្ស៊ី ថានិយាយមិនត្រូវប្រធានបទ ហើយបានលើកឡើងថា អ្នកតំណាងរាស្ត្ររូបនេះនឹងត្រូវគេប្តឹង បើសិនជាមិនមានអភ័យឯកសិទ្ធសភាទេនោះ ដោយសារតែចោទគេថាសុទ្ធតែជាម៉ាហ្វីយ៉ា។

អ្នកតំណាងរាស្ត្រ ហូ ណូន មកពីគណបក្ស ប្រជាជនកម្ពុជា បានបន្តវាយប្រហារអ្នកតំណាងរាស្ត្រ សម រង្ស៊ី ថា "ឯកឧត្តមថា ស្រឡាញ់ប្រទេស តែបែរជាបំផ្លាញផលប្រយោជន៍របស់ប្រទេសទៅវិញទេ ព្រោះមិនឱ្យអ្នកវិនិយោគចូលមក"។

អ្នកតំណាងរាស្ត្រ ជាម ច័ន្ទនី មកពីគណបក្ស សមរង្ស៊ី បានហៅការព្រួតគ្នាវាយប្រហារពាក្យសម្ដីទៅអ្នកតំណាងរាស្ត្រ សម រង្ស៊ី ថា ជាការបំបាក់ស្មារតី ហើយលើកឡើងថាមនុស្សមានមាត់ មានសារតីគឺត្រូវតែនិយាយ។

## បញ្ហាដីធ្លីធ្វើឱ្យអ្នកតំណាងរាស្ត្រ ០១ រូប ទទួលរងការវាយប្រហារ

ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានធ្វើសេចក្ដីរាយការណ៍ថា អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមមួយរូបដែលរស់នៅក្នុងទីក្រុងភ្នំពេញ បានទទួលរងរបួសជាទម្ងន់ដោយសារពលរដ្ឋមួយរូបដែលជាជនរងគ្រោះដោយសារទំនាស់ដីធ្លី បានលួចធ្វើការវាយប្រហារ។

តាមប្រព័ន្ធផ្សព្វផ្សាយនានាបានឱ្យដឹងថា អ្នកតំណាងរាស្ត្រ ជិន គីមស្រេង អាយុ ៧០ ឆ្នាំ មកពីគណបក្សប្រជាជនកម្ពុជា ត្រូវបានយុវជនដែលមានវិបត្តិផ្លូវចិត្តដោយសារតែទំនាស់ដីធ្លីវាយប្រហារនឹងដែកបំពង់ទីប នៅពេលដែលអ្នកតំណាងរាស្ត្ររូបនេះចុះពីរថយន្តដើម្បីដើរចូលផ្ទះ។

ប្រព័ន្ធផ្សព្វផ្សាយដែលស្រង់សម្ដីពីអាជ្ញាធរប៉ូលីសខណ្ឌចំការមនបានឱ្យដឹងថា ជនលេស ឈ្មោះ រស់ វណ្ណា អាយុ ២៨ ឆ្នាំ បានសារភាពថា រូបគេដាច់ចិត្តវាយអ្នកតំណាងរាស្ត្រ ជិន គីមស្រេង គឺដោយសារតែខ្លួនមានកំហឹងជាមួយអ្នកមានអំណាចយកដីរបស់ខ្លួន ហើយរូបគេក៏ប្ដឹងទៅតុលាការ ក៏ប៉ុន្តែមិនឃើញមានដំណោះស្រាយ។

សារព័ត៌មាន ឌឹឃេមបូឌាដេលី ផ្សាយថ្ងៃទី ១៥ មករា ឆ្នាំ ២០០៨ បានស្រង់សម្ដីរបស់ម្ដាយយុវជន រស់ វណ្ណា ថា "កូនប្រុសរបស់គាត់មានសភាពឡប់ៗដោយសារតែការពន្យារពេលរបស់តុលាការក្នុងការដោះស្រាយជម្លោះលើដីធ្លីរបស់ពួកគាត់ "។

សារព័ត៌មានដដែលនេះបានឱ្យដឹងថា អ្នកតំណាងរាស្ត្រ ជិន គីមស្រេង បានធូរស្រាលច្រើនហើយ។

ខុមហ្វ្រែល សូមសម្ដែងនូវការសោកស្ដាយ ដែលអ្នកតំណាងរាស្ត្រ ជិន គីមស្រេង ទទួលរងនូវការវាយប្រហារបែបនេះ។ ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្រគ្រប់រូប គួរយកចិត្តទុកដាក់ថែមទៀតចំពោះម្ចាស់ឆ្នោតរបស់ខ្លួនដែលរងគ្រោះដោយសារវិបត្តិដីធ្លី រហូតដល់មានជម្ងឺវិកលចរិត និងប្រព្រឹត្តអំពើហិង្សាលើតំណាងរបស់ខ្លួន។

ព្រឹត្តិការណ៍ក៏បញ្ជាក់ឱ្យឃើញផងដែរថា វិបត្តិដីធ្លីសព្វថ្ងៃនេះកាន់តែមានសភាពអាក្រក់ទៅៗ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ជាអាទិភាពពីសំណាក់មន្ត្រីជាប់ឆ្នោតទាំងអស់។

## រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្ម

រដ្ឋសភាក្នុងខែមករានេះ បានអនុម័តការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា ១៤៥ ថ្មី និង ១៤៦ ថ្មី ដោយបានកែប្រែពាក្យពេចន៍មួយចំនួនដើម្បីឱ្យវាស្របទៅនឹងស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជា។

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ស ខេង ដែលបានមកការពារសេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា ១៤៥ ថ្មី និង ១៤៦ ថ្មី បានឱ្យដឹងថា គោលបំណងនៃការធ្វើវិសោធនកម្មនេះ គឺដើម្បីបង្កភាពងាយស្រួលក្នុងការរៀបចំទម្រង់ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ តាមគោលនយោបាយវិមជ្ឈការ ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលក្រោមជាតិ ព្រោះសភាពការណ៍ជាក់ស្ដែងបច្ចុប្បន្នរបស់យើង វាមិនដូចគ្នាទៅនឹងខមសារដែលចែងក្នុងរដ្ឋធម្មនុញ្ញនោះទេ។ ឯកឧត្តម ស ខេង បានលើកឧទាហរណ៍ថា ឃុំប៉ោយប៉ែត (ដែលមានប្រជាពលរដ្ឋរស់នៅយ៉ាងច្រើន) មិនអាចឱ្យនៅចំណុះស្រុកអូរជ្រៅបានទៀតទេ ព្រោះស្រុកអូរជ្រៅមិនអាចគ្រប់គ្រងឃុំ ប៉ោយប៉ែត បានទេ។ ដូចនេះឃុំប៉ោយប៉ែតត្រូវបង្កើតទៅជាក្រុងមួយដែលចំណុះឱ្យខេត្តបន្ទាយមានជ័យ។

មាត្រា ១៤៥ ថ្មី ដែលចែងថា "ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង។ ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ។ ក្រុងចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់" ត្រូវបានកែប្រែទៅជា " ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបែងចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ហើយមាត្រា ១៤៦ ថ្មី ដែលចែងថា "ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់

រៀបចំអង្គការមួយ"។ ត្រូវបានកែប្រែថា "រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដែលមានចែកក្នុងច្បាប់រៀបចំអង្គការ "។

ក្នុងអំឡុងពេលពិភាក្សាវិសោធនកម្មរដ្ឋធម្មនុញ្ញ អ្នកតំណាងរាស្ត្រមួយចំនួនបានផ្តោត និងលើកឡើងពីច្បាប់រៀបចំអង្គការ ដោយស្នើឱ្យមានការចែងឱ្យច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ។

អ្នកតំណាងរាស្ត្រ សម រង្ស៊ី បានថ្លែងថា ច្បាប់រៀបចំអង្គការ ដែលរដ្ឋាភិបាលកំពុងតែព្រាងនៅឡើយ គួឱ្យមានការបោះឆ្នោតជាសាកលក្នុងការជ្រើសរើសក្រុមប្រឹក្សាក្រុង ខេត្ត ស្រុក ខណ្ឌ។ ទោះបីយ៉ាងណា តំណាងរាជរដ្ឋាភិបាល និងអ្នកតំណាងរាស្ត្រ សម្តេច ហ៊ុន សែន បានមានប្រសាសន៍ថា ច្បាប់រៀបចំអង្គការនឹងត្រូវពិភាក្សានៅពេលក្រោយ ហើយការពិភាក្សានៅពេលនេះការកែប្រែពាក្យពេចន៍ប៉ុណ្ណោះ។